# សិក្ខាសាលាបណ្តុះបណ្តាលស្តីពីជីវសុវត្ថិភាពមន្ទីរពិសោធន៍ និងការគ្រប់គ្រង ជីវហានិភ័យផ្នែកទី១

# ផ្នែកទី ១ ៖ ជីវសុវត្ថិភាពកម្រិតមូលដ្ឋាន

## ១.៨. ការអភិវឌ្ឍកម្មវិធីគ្រប់គ្រងហានិភ័យ

# នៅចុងបញ្ចប់នៃម៉ូឌុលនេះ អ្នកគួរមានសមត្ថភាព៖

- យល់ច្បាស់អំពីអត្ថប្រយោជន៍នៃការអនុវត្តកម្មវិធីគ្រប់គ្រងជីវហានិភ័យនៅក្នុងមន្ទីរពិសោធន៍
- យល់ច្បាស់ថា សវនកម្ម ត្រូវបានប្រើប្រាស់ជារង្វាស់នៃការអនុវត្តការងារគ្រប់គ្រងជីវហានិភ័យ
- វាយតម្លៃលទ្ធផលដែលទទួលបានក្រោយពីការវាយតម្លៃ
- យល់ច្បាស់ថា កម្មវិធីបណ្តុះបណ្តាលសុវត្ថិភាពពេលកំពុងបំពេញការងារដែលត្រូវបានធ្វើឡើងជាបន្តបន្ទាប់ គឺមានភាពចាំបាច់ណាស់ដើម្បីរក្សាការយល់ដឹងស្តីអំពីសុវត្ថិភាពរបស់បុគ្គលិកមន្ទីរពិសោធន៍ និងបុគ្គលិកផ្តល់ការគាំទ្រដទៃទៀតនៅក្នុងមន្ទីរពិសោធន៍
- ដឹងអំពីសារៈសំខាន់នៃកម្មធីសុខភាព សម្រាប់បុគ្គលិកមន្ទីរពិសោធន៍
- បង្កើតបញ្ជីសារពើភ័ណ្ឌ សម្រាប់ផ្គត់ផ្គង់សម្ភារៈ និងមេរោគ

# ទិដ្ឋភាពទូទៅ

- ការរក្សាកម្មវិធីជីវសុវត្ថិភាព៖ ការពិនិត្យតាមដាន និងវាយតម្លៃ
- ការវាយតម្លៃ និងសវនកម្មមន្ទីរពិសោធន៍
- ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនៅក្នុងមន្ទីរពិសោធន៍
- កម្មវិធីសុខភាពសម្រាប់បុគ្គលិកមន្ទីរពិសោធន៍។ ការកំណត់កម្មវិធីចាក់ថ្នាំបង្ការដែលពាក់ព័ន្ធសម្រាប់ការងារនៅក្នុងមន្ទីរពិសោធន៍នីមួយៗ
- សារៈសំខាន់នៃការធ្វើបញ្ជីសារពើភ័ណ្ឌមន្ទីរពិសោធន៍ រួមទាំងសម្រាប់សម្ភារៈផ្គត់ផ្គង់ និងមេរោគ

# តើហេតុអ្វីបានជាត្រូវអនុវត្តកម្មវិធីគ្រប់គ្រងជីវហានិភ័យ?

# ហានិភ័យសំខាន់ៗកើតនៅក្នុង និងចេញពីគ្រឹះស្ថានជីវសាស្ត្រ

## សម្រាប់បុគ្គលិក

- ការប្រឈមដោយផ្ទាល់ តាមរយៈការប៉ះ (ដៃ មាត់ ភ្នែក...)
- ការហើរនៅក្នុងខ្យល់ (ការបញ្ជូនចូលតាមប្រព័ន្ធដកដង្ហើម ក៏ដូចជាការប្រឡាក់មេរោគឆ្លង)
- វត្ថុមុតស្រួច...

## សម្រាប់សហគមន៍ (គ្រួសារ អ្នកជិតខាង...)

- ការចម្លងចេញដោយបុគ្គលិកដែលមានមេរោគ
- ការចម្លងចេញតាមរយៈវត្ថុប្រឡាក់មេរោគ (ដៃ វត្ថុ កាកសំណល់...)
- ការសាយភាយតាមខ្យល់ (តាមរយៈមេរោគដែលហើរនៅក្នុងខ្យល់)
- ការចម្លងចេញដោយកាកសំណល់រាវ

## សម្រាប់បរិស្ថាន

- ការសាយភាយតាមខ្យល់ (តាមរយៈមេរោគដែលហើរនៅក្នុងខ្យល់)
- ការប្រឡាក់មេរោគតាមរយៈកាកសំណល់រឹង និងរាវ

# តើអ្វីជាជីវសុវត្ថិភាពប្រកបដោយប្រសិទ្ធភាព?

ការការពារប្រកបដោយប្រសិទ្ធភាព៖

ការទប់ស្កាត់ការប្រឈម(ការប៉ះពាល់ដោយផ្ទាល់ ការហើរក្នុងខ្យល់ វត្ថុមុតស្រួច...)

- ការអនុវត្តដោយសុវត្ថិភាពពិតជាមាននៅនឹងកន្លែង ហើយត្រូវបានប្រើប្រាស់
- ឧបករណ៍ការពារបុគ្គលពិតជាត្រូវបានស្លៀកពាក់

ការទប់ស្កាត់ការចម្លងមេរោគ និងការសាយភាយ

- ហេដ្ឋារចនាសម្ព័ន្ធរាំងខ្ទប់ការសាយភាយមេរោគដំណើរការត្រឹមត្រូវ (ការគ្រប់គ្រងលើការភាយនៅក្នុងខ្យល់ ប្រព្រឹត្តកម្មកាកសំណល់...)
- វិធានការរាំងខ្ទប់ការសាយភាយមេរោគ (ការលាងដៃ ការញែកសំរាម...) ជាក់ស្តែងត្រូវបានអនុវត្តតាម

**ចាំបាច់ត្រូវតែធានាថាវិធានការមានលក្ខណៈសមស្រប ហើយជាក់ស្តែងពិតជាត្រូវបានអនុវត្ត**

# សមាសធាតុនៃកម្មវិធីជីវសុវត្ថិភាព




- ការលាងដៃ
- ការពាក់ស្រោមដៃ
- ការអនុវត្តការសម្លាប់មេរោគ

- ការបណ្ដុះបណ្ដាល
- ព័ត៌មាន
- ការវាយតម្លៃហានិភ័យ
- អធិការកិច្ច និងសវនកម្ម

- គ្រឹះស្ថាន
- ឧបករណ៍

# ការអនុវត្តក្នុងការចាត់ចែង និងការការពារបុគ្គល

- សំខាន់គឺជាបញ្ហានៃការយល់ដឹង ការអប់រំ និងការបណ្តុះបណ្តាល
- ប្រវត្តិ៖
  - ជាមធ្យោបាយការពារតែមួយមុខគត់អស់ពេលជាច្រើនឆ្នាំ
  - ការថយចុះចំនួនការឆ្លងរោគពីមន្ទីរពិសោធន៍ ទាក់ទងជាមួយការអភិវឌ្ឍការយល់ដឹង និងអនាម័យ និងការអនុវត្តការងារប្រកបដោយសុវត្ថិភាព
- អនុញ្ញាតឲ្យដាក់ដែនកំណត់លើហានិភ័យនៃការប៉ះជាមួយមេរោគ ឲ្យបានភាគច្រើន នៅក្នុងបរិយាកាសប្រក្រតី
  - បញ្ហាចំបងដែលនៅសល់ = ការគ្រប់គ្រងការឆ្លងមេរោគនៅក្នុងខ្យល់
- បញ្ហាប្រឈមផ្នែកធនធានមានកំណត់ ក្នុងប្រទេសនិងអង្គភាពមួយចំនួន
  - ខ្វះការបណ្តុះបណ្តាល និងខ្វះលទ្ធភាពបណ្តុះបណ្តាល
  - គ្រឹះស្ថានមិនសមស្រប (មន្ទីរពិសោធន៍មានការរចនាអន់ មិនមានអាងលាងដៃ...)
  - ការចំណាយលើឧបករណ៍ការពារបុគ្គល (PPE) និងផលិតផលនានា

# ហេដ្ឋារចនាសម្ព័ន្ធ៖ អាគារ និងឧបករណ៍

- បញ្ហាទាក់ទងជាមួយការរចនា វិស្វកម្ម និងការថែទាំសមស្រប
- ប្រវត្តិ៖
  - ការអភិវឌ្ឍនៃឧបករណ៍ការពារ (គម្របស្រេបផ្សេង បន្ទាប់មកមានទូរជីវសុវត្ថិភាព) បន្ទាប់មកមានទស្សនាទានស្តីពីអាគាររាំងខ្ទប់ការសាយភាយមេរោគ
  - បច្ចេកវិជ្ជាកាន់តែជឿនលឿនឡើងៗ (ឧ. នៅក្នុងការគ្រប់គ្រងផ្នែកវិស្វកម្ម និងស្វ័យប្រវត្តិកម្ម)
- ការអនុញ្ញាតមានកំរិតកំណត់ចំពោះការប៉ះពាល់ និងការសាយភាយមេរោគ រួមទាំងការសាយភាយមេរោគនៅក្នុងខ្យល់

# ហេដ្ឋារចនាសម្ព័ន្ធ៖ អាគារ និងឧបករណ៍

- បញ្ហាប្រឈមផ្នែកធនធានមានកំណត់ ក្នុងប្រទេសនិងអង្គការមួយចំនួន
  - ការវិនិយោគ និងថ្លៃប្រតិបត្តិការខ្ពស់ (ហួសកម្រិត?)
  - ខ្វះវិស្វករឯកទេសជំនាញ
  - ខ្វះធនធានថែទាំ (ចំណោះធ្វើ គ្រឿងបន្លាស់...)
  - ខ្វះបទបញ្ញត្តិ និងបទដ្ឋានក្នុងប្រទេស (និងកែសម្រួលពីខាងក្រៅ!)

# ការត្រួតពិនិត្យ និងគ្រប់គ្រងទូទៅ

- បញ្ហាចម្បងគឺទាក់ទងនឹងការយល់ដឹង ការអប់រំ និងអង្គភាព
- ប្រវត្តិ៖
  - ការអភិវឌ្ឍកម្មវិធីជីវសុវត្ថិភាពមានរចនាសម្ព័ន្ធត្រឹមត្រូវ (សៀវភៅណែនាំ នីតិវិធី...)
  - ការអភិវឌ្ឍនាពេលថ្មីៗនេះនៃប្រព័ន្ធការគ្រប់គ្រង (ISO, CWA...)
- អនុញ្ញាតឲ្យមានការត្រួតពិនិត្យជាទូទៅលើកម្មវិធីទាំងនេះ រួមទាំងការចាត់ចែងធនធាន ការអនុវត្តវិធានការ និងដំណើរការនៃការផ្ទៀងផ្ទាត់
- បញ្ហាប្រឈមផ្នែកធនធានមានកំណត់ ក្នុងប្រទេសនិងអង្គការមួយចំនួន
  - កង្វះការយល់ដឹងនៅក្នុងស្ថាប័នមួយចំនួន
  - ទិដ្ឋភាពផ្នែកវប្បធម៌?

# និន្នាការបស្ទឹមប្រទេសក្នុងការគ្រប់គ្រងហានិភ័យ

- ឋានានុក្រមនៃវិធានការគ្រប់គ្រងហានិភ័យ៖
  1. ការគ្រប់គ្រងផ្នែកវិស្វកម្ម
  2. នីតិវិធីធ្វើការងារ៖ ត្រូវបានកែសម្រួលទៅតាមការគ្រប់គ្រងផ្នែកវិស្វកម្ម
  3. PPE – ក្នុងករណីដែលមានចែងក្នុងចំនុច 1 និង 2 ខាងលើ មិនគ្រប់គ្រាន់ដើម្បីធានានូវការការពារ!
- ត្រូវបានអភិវឌ្ឍដំបូងនៅក្នុងឧស្សាហកម្មឱសថ បន្ទាប់មកក៏ឈានទៅកាន់បរិយាកាសដ៏ទៃទៀត

# និន្នាការបស្នឹមប្រទេសក្នុងការគ្រប់គ្រងហានិភ័យ

- *តើមានអ្វីខ្លះនៅពីក្រោយអភិក្រមនេះ?*
  - ទំនុកចិត្តយ៉ាងខ្លាំងទៅលើ "បច្ចេកវិទ្យា" និង "វិស្វកម្ម"
  - មានការយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាហានិភ័យ
  - ការចំណាយខ្ពស់លើកម្លាំងពលកម្មមនុស្ស
  - ការរកទីផ្សារ / ការពិចារណាផ្នែកលក់

# តើគំរូបស្ទឹមប្រទេសបានផល ឬទេ?

មន្ទីរពិសោធន៍៖ ជំងឺឆ្លង ឧបទ្ទវហេតុ ឬគ្រោះថ្នាក់

- នៅតែកើតមាន បើទោះជាពេលខ្លះមន្ទីរពិសោធន៍នោះមានប្រព័ន្ធគ្រប់គ្រងល្អឥតខ្ចោះក៏ដោយ។
- មូលហេតុអាចមកពី៖
  - កំហុសរបស់មនុស្ស ឬការធ្វេសប្រហែស
  - កំហុសបច្ចេកទេស
  - ជារឿយៗ ច្រើនតែជាបន្សំនៃកំហុសបច្ចេកទេស និងកំហុសមនុស្ស
- ជារឿយៗ ច្រើនពាក់ព័ន្ធជាមួយបញ្ហាការគ្រប់គ្រង

# តើគំរូបស្ទឹមប្រទេសបានផល ឬទេ?

តើអភិក្រមបស្ទឹមប្រទេសបានផល ឬទេ? បានផល ឲ្យតែ៖

- ឧបករណ៍មានការរចនាល្អ ប្រតិបត្តិការល្អ និងថែទាំបានល្អ
- ឧបករណ៍ត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវ សារៈសំខាន់នៃការបណ្តុះបណ្តាល និងការអនុវត្ត
- មានវត្តមានប្រព័ន្ធគ្រប់គ្រងល្អ

# បញ្ហាសុវត្ថិភាព និងសន្តិសុខ អាស្រ័យដោយ បញ្ហានៅក្នុងការគ្រប់គ្រងជីវហានិភ័យ

• សាកលវិទ្យាល័យ Texas A&M សហរដ្ឋអាមេរិច ឆ្នាំ២០០៦-២០០៧ មន្ត្រីសហព័ន្ធអាមេរិចបានព្យួរការស្រាវជ្រាវលើការជ្រើសរើសភ្នាក់ងារបង្ករោគទាំងអស់ (Select Agent research) អាស្រ័យដោយការខកខានមិនបានរាយការណ៍លើករណីឧបទ្ទវហេតុចំនួនពីរ។

•មន្ទីរពិសោធន៍ Pirbright វិទ្យាស្ថានសុខភាពសត្វ ចក្រភពអង់គ្លេស ឆ្នាំ ២០០៧ ការជ្រាបចេញពីបំពង់នៅក្នុងប្រព័ន្ធបង្ហូរកាកសំណល់បង្កឲ្យមានការផ្ទុះជំងឺជើង និងមាត់ (Foot and Mouth Disease) ។ គេបានរកឃើញថាបំពង់នោះគឺត្រូវការ ការថែទាំ ។


TAMU Select Agent researcher
Dallas Morning News


Thomas Butler

# បញ្ហាសុវត្ថិភាព និងសន្តិសុខ អាស្រ័យដោយ បញ្ហានៅក្នុងការគ្រប់គ្រងជីវហានិភ័យ

- សាស្រ្តាចារ្យ Thomas Butler សហរដ្ឋអាមេរិច ឆ្នាំ២០០៣ មេរោគ *Yesinia pestis* ចំនួន ៣០ កូនដប បានបាត់ពីមន្ទីរពិសោធន៍ (មិនដែលត្រូវបានរកឃើញមកវិញទេ) Butler ត្រូវជាប់ពន្ធនាគាររយៈពេល ១៩ខែ
- ការផ្ទុះជំងឺ SASRS ចម្លងចេញពីមន្ទីរពិសោធន៍ ឆ្នាំ ២០០៣-២០០៤
ប្រទេសសិង្ហបុរី ខែកញ្ញា ឆ្នាំ ២០០៣
ប្រទេសតៃវ៉ាន់ (ចិន) ខែធ្នូ ឆ្នាំ ២០០៣
ទីក្រុងប៉េកាំង និងខេត្តអានហ្វួយ (ចិន) ខែមីនា ឆ្នាំ ២០០៤


TAMU Select Agent researcher
Dallas Morning News


Thomas Butler

# មេរៀនដែលទទួលបាន

ឧបករណ៍បច្ចេកទេស និងការគ្រប់គ្រងផ្នែកវិស្វកម្មគ្មានប្រយោជន៍ (ហើយអាចមានលទ្ធភាពបង្កគ្រោះថ្នាក់)

- ប្រសិនបើត្រូវបានរចនាយ៉ាងអន់ ឬមិនសមស្រប
- ប្រសិនបើមិនអាចគ្រប់គ្រងបាន
- ប្រសិនបើមិនអាចជឿទុកចិត្តបាន ("ការយល់ខុសឆ្គងអំពីសុវត្ថិភាព"

# មេរៀនដែលទទួលបាន

ការអនុវត្តក្នុងការចាត់ចែងការងារដោយប្រើប្រាស់ឧបករណ៍អាចទុកចិត្តបាន និង PPE ផ្តល់ការការពារក្នុងកម្រិតល្អ

- ប្រសិនបើសមស្របចំពោះការងារ និង ប្រភេទគ្រោះថ្នាក់ ព្រមទាំងកម្រិតនៃហានិភ័យ
- ប្រសិនបើត្រូវបានគោរពតាមក្នុងការអនុវត្តជាក់ស្តែង (បញ្ហាស្តីពីភាពអនុលោមតាមច្បាប់)

# មេរៀនដែលទទួលបាន

ការគ្រប់គ្រង និង*ភាពជាអ្នកដឹកនាំ* គឺជាដើមទុន

- ដើម្បីធានាថា ការវាយតម្លៃហានិភ័យដែលចាំបាច់ត្រូវបានធ្វើឡើង និងបានយកមកពិចារណា
- ដើម្បីកំណត់រកតម្រូវការក្នុងការការពារ ព្រមទាំងវិធានប្រតិបត្តិការ
- ដើម្បីធានាឲ្យមាននីតិវិធីសមស្របនៅនឹងកន្លែង និងមានការអនុវត្តតាមនីតិវិធីទាំងនោះ
- ដើម្បីធានាឲ្យមានការបណ្តុះបណ្តាលសមស្របសម្រាប់បុគ្គលិកមន្ទីរពិសោធន៍
- ដើម្បីធានាឲ្យបានថា ការថែទាំត្រូវបានធ្វើឡើង

# តើធ្វើយ៉ាងណាដើម្បីចៀសវាងបញ្ហាស្រដៀងគ្នា?

កម្មវិធីគ្រប់គ្រងជីវហានិភ័យមន្ទីរពិសោធន៍ចាំបាច់ត្រូវ៖

- មានធនធានសមស្រប
- មានគោលការណ៍ណែនាំរបស់ស្ថាប័ន និងនីតិវិធីប្រតិបត្តិការ
- មានការបណ្តុះបណ្តាល
- មានការមើលខុសត្រូវ

# តើធ្វើយ៉ាងណាដើម្បីចៀសវាងបញ្ហាស្រដៀងគ្នា?

ប៉ុន្តែ៖

តើត្រូវធ្វើយ៉ាងណាដើម្បីសម្រេចចិត្តលើការចាត់ចែងធនធាន?

តើត្រូវធ្វើយ៉ាងណាដើម្បីកំណត់ថា អ្វីដែលត្រូវការឆ្លើយតបនៅក្នុងនីតិវិធីប្រតិបត្តិការ?

តើត្រូវធ្វើយ៉ាងណាដើម្បីកំណត់ថា ការបណ្តុះបណ្តាលអ្វីខ្លះដែលចាំបាច់សម្រាប់នរណា?

តើត្រូវធ្វើយ៉ាងណាដើម្បីកំណត់ថា តើការមើលខុសត្រូវកម្រិតណាមានភាពសមស្រប?

# អភិក្រមការគ្រប់គ្រងជីវហានិភ័យ

ត្រូវការក្របខ័ណ្ឌការងារដ៏រឹងមាំ ដើម្បីអនុវត្តកម្មវិធីក្នុងការគ្រប់គ្រងជីវហានិភ័យ
មានធាតុជាច្រើនដែលត្រូវដាក់បញ្ចូល

ឧទាហរណ៍~~អំពី~~៖ប្រព័ន្ធគ្រប់គ្រងដែលត្រូវបានប្រើប្រាស់ក្នុងមន្ទីរពិសោធន៍
ISO 9001:2000 ៖ ប្រព័ន្ធគ្រប់គ្រងគុណភាព
ISO 14001:2004៖ ៖ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន
OHSAS 18001:2007៖៖ ប្រព័ន្ធគ្រប់គ្រងសុខភាពវិជ្ជាជីវៈ និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព

កិច្ចព្រមព្រៀងសិក្ខាសាលា CEN ឆ្នាំ ២០០៨៖ ប្រព័ន្ធគ្រប់គ្រងជីវហានិភ័យមន្ទីរពិសោធន៍
អភិក្រមផ្អែកលើហានិភ័យ

ទាំងអស់នេះ ពឹងផ្អែកលើអភិក្រម "ផែនការ-ធ្វើ-ពិនិត្យ-ធ្វើសកម្មភាព" ដោយមានគោលបំណងដើម្បីបន្តកែលម្អជាប្រចាំ

# និងដោយមានការអនុវត្តកម្មវិធីគ្រប់គ្រងជីវហានិភ័យប្រកបដោយប្រសិទ្ធភាព...

ការលើកកម្ពស់ការប្រើប្រាស់ភ្នាក់ងារជីវសាស្ត្រ ឧបករណ៍ និងជំនាញការប្រកបដោយការទទួលខុសត្រូវនៅទូទាំងសកលលោក ពង្រឹងសមត្ថភាព ដើម្បីពិនិត្យ ចាត់ចែង និងគ្រប់គ្រងដោយសុវត្ថិភាព សន្តិសុខ និងការទទួលខុសត្រូវលើភ្នាក់ងារជីវសាស្ត្រគ្រោះថ្នាក់

កែលម្អការយល់ដឹង និងការគ្រប់គ្រងលើហានិភ័យពាក់ព័ន្ធជាមួយការប្រើប្រាស់បំពាន ដោយចៃដន្យ និងដោយចេតនានៃភ្នាក់ងារជីវសាស្ត្រ

# ការរចនាហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាព

- ហេដ្ឋារចនាសម្ព័ន្ធ (គ្រឹះស្ថាន និងឧបករណ៍) គួរត្រូវបានមើលឃើញថា ជាវិធីមួយដើម្បីសម្រួលដល់ប្រតិបត្តិការប្រកបដោយសុវត្ថិភាព ជាជាងដំណោះស្រាយចុងក្រោយបំផុត
- ការរចនាគ្រឹះស្ថានតម្រូវឲ្យពិចារណាលើ
  - សេចក្តីត្រូវការរបស់ស្ថាប័ន និងអ្នកប្រើប្រាស់
  - ប្រភេទគ្រោះថ្នាក់ និងកម្រិតនៃហានិភ័យ
  - ធនធាន (ហិរញ្ញវត្ថុ បច្ចេកទេស និងមនុស្ស) ដែលចាំបាច់ដើម្បីប្រតិបត្តិការគ្រឹះស្ថាន

បទដ្ឋានបច្ចេកទេស និងដំណោះស្រាយ "ចម្លងដូចបេះបិទ" ត្រូវបានប្រើប្រាស់តែក្នុងករណីដែលបទដ្ឋានដំណោះស្រាយទាំងនោះឆ្លើយតបចំពោះសេចក្តីត្រូវការជាក់ស្តែង ហើយអាចសម្រេចបាន និងរក្សានិរន្តភាពបានប៉ុណ្ណោះ

- ការរចនាគ្រឹះស្ថានរាំងខ្ទប់មិនឲ្យមេរោគសាយភាយ គឺជាភារកិច្ចដ៏ស្មុគស្មាញដែលតម្រូវឲ្យមានសមត្ថភាពពហុជំនាញ (ផ្នែកវិទ្យាសាស្ត្រ ផ្នែកបច្ចេកទេស...) ធនធានសមស្រប (រួមទាំងពេលវេលា) និងការគ្រប់គ្រងល្អ

# ការអនុវត្តវិធីធ្វើការងារប្រកបដោយប្រសិទ្ធភាព

- ការអនុវត្តប្រកបដោយសុវត្ថិភាព គឺជាធាតុ ***គន្លឹះ*** នាំមកជីវសុវត្ថិភាពមានប្រសិទ្ធភាព
- ការអនុវត្តចាំបាច់ត្រូវសម្របទៅតាម
  - សកម្មភាព (ងាយស្រួលប្រតិបត្តិការ អាចអនុវត្តបាន មានប្រសិទ្ធភាព/ប្រសិទ្ធផលវិទ្យា...)
  - ប្រភេទគ្រោះថ្នាក់ និងកម្រិតហានិភ័យ
  - ហេដ្ឋារចនាសម្ព័ន្ធ

# ការអនុវត្តវិធីធ្វើការងារប្រកបដោយប្រសិទ្ធភាព

- ការអនុវត្ត ចាំបាច់ត្រូវ
  - កំណត់ច្បាស់លាស់ (នីតិវិធីជាលាយលក្ខណ៍អក្សរ)
  - អាចអនុវត្តបាន/អាចធ្វើបាន (បង្កើតឡើងដោយមនុស្សដែលពាក់ព័ន្ធ?)
  - ត្រូវបានគេដឹង និងយល់ជាទូលំទូលាយ (ការបណ្ដុះបណ្ដាល)
  - ត្រូវបានប្រើប្រាស់*ជាក់ស្ដែង* ដោយមនុស្សពាក់ព័ន្ធ*ទាំងអស់* (ដំណើរការក្នុងការពិនិត្យ៖ ការគ្រប់គ្រងមន្ទីរពិសោធន៍ អធិការកិច្ច និងការអនុវត្តការធ្វើសវនកម្ម)

# ការអនុវត្តកម្មវិធីធ្វើប្រកបដោយប្រសិទ្ធភាព

ការវាយតម្លៃហានិភ័យ នីតិវិធី និងការអនុវត្ត ការគ្រប់គ្រងមន្ទីរពិសោធន៍ ការបណ្តុះបណ្តាល អធិការកិច្ច និងសវនកម្ម…

- ➔ចំណុចទាំងអស់នេះ ចាំបាច់ត្រូវមានការរៀបចំនៅក្នុងកម្មវិធីសាកល បែបរួមបញ្ចូល ដោយក្នុងនោះក៏ត្រូវកំណត់
  - ➔គោលនយោបាយ គោលបំណង និងការទទួលខុសត្រូវ
  - ការចាត់ចែងធនធាន

# ការអនុវត្តកម្មវិធីធ្វើប្រកបដោយប្រសិទ្ធភាព

ឧបករណ៍វាយតម្លៃដ៏មានប្រយោជន៍ = ‘ការគ្រប់គ្រងជីវហានិភ័យមន្ទីរពិសោធន៍’ CWA15793:2011

- ផ្អែកលើការវាយតម្លៃហានិភ័យ និង ការទទួលខុសត្រូវ
- អនុញ្ញាតឲ្យកែសម្រួល និងសម្របទៅតាមសេចក្តីត្រូវការរបស់ស្ថាប័ន (ពុំមែនជាបទដ្ឋានបច្ចេកទេស)
- ជាវិធីមួយ ដើម្បីត្រូវបានគេទទួលស្គាល់ រួមទាំងនៅកម្រិតអន្តរជាតិផងដែរ

# ការគ្រប់គ្រងជីវសុវត្ថិភាពប្រកបដោយប្រសិទ្ធភាព

**ហេដ្ឋារចនាសម្ព័ន្ធ +ការអនុវត្ត+ ការគ្រប់គ្រង**

- មានវត្ថុមានឧបករណ៍វាយតម្លៃ និងដំណោះស្រាយជាច្រើន ប៉ុន្តែឧបករណ៍វាយតម្លៃ និងដំណោះស្រាយទាំងអស់នោះ ប្រហែលជាពុំមែនសុទ្ធតែត្រូវបានសម្របតាមសេចក្តីត្រូវការជាក់ស្តែងនោះឡើយ
- ហេតុនេះ មិនចាំបាច់ត្រូវធ្វើសារឡើងវិញនូវអ្វីគ្រប់យ៉ាងពីខាងដើមមកវិញឡើយ ប៉ុន្តែ៖

  - សូមគិតអំពីជីវសុវត្ថិភាព (និងជីវសន្តិសុខ) ពាក់ព័ន្ធជាមួយសេចក្តីត្រូវការ និងមធ្យោបាយរបស់អ្នក
  - ធានាយ៉ាងណាឲ្យដំណោះស្រាយដែលអ្នកជ្រើសរើស ត្រូវបានសម្របទៅតាមសេចក្តីត្រូវការ បរិបទ និងលទ្ធភាព (ហិរញ្ញវត្ថុ ការថែទាំ ភ័ស្តុភារ...) របស់អ្នក
  - អភិវឌ្ឍចំណេះដឹង និងជំនាញដើម្បីអាចយល់អំពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងជីវៈ ហានិភ័យ (រួចហើយធ្វើការជ្រើសរើសយកជម្រើសសមស្របបំផុត ជម្នះលើអ្នកផ្គត់ផ្គង់...!)

# ការចងក្រងជាឯកសារ

- សំណៅគោលការណ៍ណែនាំថ្នាក់ជាតិ៖









- ការវាយតម្លៃហានិភ័យគ្រឹះស្ថាន
- ការអនុវត្តជីវសុវត្ថិភាព  និងSOPs ជាក់លាក់សំរាប់គ្រឹះស្ថាន
- ផែនការត្រៀមទុកជាមុនសម្រាប់ករណីមានគ្រោះថ្នាក់

# ការចងក្រងជាឯកសារ

- សៀវភៅណែនាំជីវសុវត្ថិភាព ការវាយតម្លៃហានិភ័យផ្ដោតជាក់លាក់លើមន្ទីរពិសោធន៍
- បញ្ជីសារពើភ័ណ្ឌ
  - ភ្នាក់ងារជីវសាស្ត្រ និងជាតិពុលរបស់មេរោគទាំងអស់ដែលត្រូវបានរក្សាទុកនៅគ្រឹះស្ថានមន្ទីរពិសោធន៍
  - សារធាតុគីមីដែលមាននៅក្នុងមន្ទីរពិសោធន៍
  - ត្រូវធ្វើបច្ចុប្បន្នភាពដោយការដាក់បន្ថែម ការបញ្ឈប់សកម្មភាព ការផ្ទេរ
- ការចងក្រងជាឯកសារសម្រាប់លទ្ធភាពចូលទៅរកសម្ភារៈគ្រោះថ្នាក់
- ការបណ្ដុះបណ្ដាល៖ ការតម្រង់ទិសអំពីសុវត្ថិភាព ការដឹកជញ្ជូន សន្តិសុខជីវសុវត្ថិភាព ការបណ្ដុះបណ្ដាលរំលឹកឡើងវិញ

# ការចងក្រងជាឯកសារ

សុខភាពវិជ្ជាជីវៈ និងសុវត្ថិភាព

- តាមដានបន្តអំពីសុខភាពរបស់បុគ្គលិកមន្ទីរពិសោធន៍
- ផ្តល់ការចាក់ថ្នាំបង្ការដល់បុគ្គលិក
- ពិនិត្យតាមដានការអនុវត្តនៅក្នុងមន្ទីរពិសោធន៍

# ការចាក់ថ្នាំបង្ការដែលចាំបាច់

## បុគ្គលិកមន្ទីរពិសោធន៍

| វិស័យការងារ | ថ្នាំបង្ការ |
|---|---|
| វត្ថុវិភាគផ្នែកពេទ្យសត្វ ឬធ្វើការជាមួយមេរោគ គ្រុន Q (Coxiella burnetii) | គ្រុន Q |
| ជាលិកាសត្វប្រចៀវ ឬ lyssaviruses (រួមបញ្ចូលទាំងវីរុសឆ្កែឆ្កួត និងlyssavirus របស់សត្វប្រចៀវអូស្ត្រាលី) | ឆ្កែឆ្កួត |
| Bacillus anthracis | Anthrax |
| Vaccinia poxviruses | អុតតូច |
| វីរុសនៃជំងឺស្វិតដៃជើងក្មេង | គ្រុនស្វិតដៃជើង |
| Salmonella enterica subspecies enterica serovar Typhi (S. Typhi) | គ្រុនពោះវៀន |
| វីរុសគ្រុនលឿង | គ្រុនលឿង |
| Neisseria meningitidis | Quadrivalent meningococcal conjugate vaccine (4vMenCV) Meningococcal B (MenBV) |
| វីរុសរលាកខួរក្បាលជេអ៊ី | Japanese encephalitis |

# ការចាក់ថ្នាំបង្ការដែលចាំបាច់

## បុគ្គលិកថែទាំសុខភាព

| វិស័យការងារ | ថ្នាំបង្ការ |
|---|---|
| បុគ្គលិកផ្នែកថែទាំសុខភាពទាំងអស់ និងសិស្សដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការថែទាំអ្នកជំងឺ ឬការចាប់កាន់ជាលិកាមនុស្សដ៏ទៃទៀត | ជំងឺរលាកថ្លើមប្រភេទ A និង B<br>គ្រុនផ្តាសាយ<br>កញ្ជ្រិល<br>ស្រឡទែន<br>ស្អូច (កញ្ជ្រិលអាល្លឺម៉ង់)<br>ក្អកមាន់ (pertussis)<br>អុតធំ (អុតស្វាយ/varicella) |
| ប្រឈមហានិភ័យប៉ះពាល់ជាមួយករណីជំងឺរបេងស៊ាំថ្នាំ | ពិចារណាតម្រូវការចាក់ថ្នាំបង្ការជំងឺរបេង tuberculosis (BCG) |

ការធ្វើតេស្តមូលដ្ឋានផ្នែកសេរ៉ូសាស្ត្រគួរត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាឯកសារ

# សារៈសំខាន់នៃការពិនិត្យតាមដាន និង វាយតម្លៃមន្ទីរពិសោធន៍

- មន្ទីរពិសោធន៍ដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធសុខាភិបាល
- ការធ្វើតេស្តគួរជាទីទុកចិត្ត និងទាន់ពេលវេលារបស់មន្ទីរពិសោធន៍ គឺជាស្នូលដ៏សំខាន់នៃការព្យាបាលអ្នកជំងឺប្រកបដោយប្រសិទ្ធភាព
- ការទប់ស្កាត់ និងការគ្រប់គ្រងលើជំងឺឆ្លង តម្រូវឲ្យមានព័ត៌មានរោគវិនិច្ឆ័យពីមន្ទីរពិសោធន៍យ៉ាងត្រឹមត្រូវ

**ការពិនិត្យតាមដាន និងការវាយតម្លៃមន្ទីរពិសោធន៍ គឺមានភាពចាំបាច់ណាស់សម្រាប់លទ្ធផលតេស្តគួរជាទីទុកចិត្ត!!**

# សវនកម្ម

## តើអ្វីជា សវនកម្ម?

ការពិនិត្យឡើងវិញដោយឯករាជ្យ ជាប្រព័ន្ធ និងស៊ីជម្រៅនៃការបំពេញមុខងាររបស់ដំណើរការ ប្រព័ន្ធ ឬអង្គការមួយ ដើម្បីវាយតម្លៃលើទំហំនៃការបំពេញការងារតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់។

- លក្ខខណ្ឌវិនិច្ឆ័យ អាចពាក់ព័ន្ធជាមួយនឹងគុណភាព (ជីវ)សុវត្ថិភាព ឬការអនុវត្តផ្នែកបរិស្ថាន
- លក្ខខណ្ឌវិនិច្ឆ័យការអនុវត្តការងារ អាចត្រូវបានកំណត់នៅក្នុងបទដ្ឋាន ឬផ្អែកលើទស្សនវិស័យហានិភ័យ
- សវនកម្ម អាចមានលក្ខណៈបច្ចេកទេសតិច ឬច្រើន ហើយរួមបញ្ចូលជាមួយទិដ្ឋភាពផ្នែកការគ្រប់គ្រង តិច ឬច្រើនផងដែរ
- គោលបំណងចុងក្រោយនៃសវនកម្ម គឺដើម្បីកែលម្អការបំពេញមុខងាររបស់ដំណើរការ ប្រព័ន្ធ ឬអង្គការ

# តើហេតុអ្វីបានជាត្រូវធ្វើសវនកម្ម?

- ការវាយតម្លៃលើការការបំពេញការងាររបស់ប្រព័ន្ធការគ្រប់គ្រង
- លុបបំបាត់ភាពមិនច្បាស់លាស់ទាក់ទងជាមួយប្រសិទ្ធភាពនៃការគ្រប់គ្រងជីវហានិភ័យ និងការអនុវត្តការគ្រប់គ្រងជីវហានិភ័យ
- សម្របសម្រួលឲ្យមានការអនុវត្តឯកភាពគ្នា ទាំងជីវសុវត្ថិភាព និងជីវៈសន្តិសុខនៅក្នុងក្រុម/នាយកដ្ឋាន/ទីតាំងផ្សេងៗគ្នា
- គូសបញ្ជាក់អំពីការយល់ដឹងរបស់ស្ថាប័នអំពីការទទួលខុសត្រូវរបស់ខ្លួន និងលើកកម្ពស់ទំនុកចិត្តពីភាគីពាក់ព័ន្ធនានា

# តើហេតុអ្វីបានជាត្រូវធ្វើសវនកម្ម?

- អាចត្រូវបានប្រើប្រាស់ជាភស្តុតាងបញ្ជាក់អំពីការគ្រប់គ្រងជីវហានិភ័យប្រកបដោយគុណភាពសម្រាប់ទីភ្នាក់ងារជំរុញការអនុវត្តច្បាប់ និង ភាគីពាក់ព័ន្ធដទៃទៀត
- សក្តានុពលនៃការទទួលខុសត្រូវជាសាធារណៈ និងសក្តានុពលនៃហានិភ័យបណ្តឹងទៅតុលាការ ត្រូវបានរំពឹងទុកជាមុន។

# ភាពខុសគ្នារវាងសវនកម្មផ្ទៃក្នុង និងសវនកម្មពីខាងក្រៅ

## សវនកម្មផ្ទៃក្នុង

សវនកម្មអនុវត្តដោយសវនកររបស់អង្គការផ្ទាល់

- សវនករផ្ទៃក្នុងមិនគួរជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនឡើយ
- ពួកគេផ្តល់ការប្រឹក្សាដល់ថ្នាក់គ្រប់គ្រង ឬមើលការខុសត្រូវលើស្ថាប័ដើម្បីធ្វើយ៉ាងណាឲ្យការអនុវត្តការទទួលខុសត្រូវរបស់ពួកគេឲ្យកាន់តែប្រសើរថែមទៀត

## សវនកម្មពីខាងក្រៅ

សវនកម្មអនុវត្តដោយសវនករក្រោមកិច្ចសន្យាជាមួយអង្គការ

- អនុញ្ញាតឲ្យអ្នកជំនាញពីខាងក្រៅ ឯករាជ្យ ផ្តល់ទស្សនៈស្តីអំពីសកម្មភាពរបស់ក្រុមហ៊ុន

# ដំណើរការ

1) ការរៀបចំធ្វើសវនកម្ម និងកាលបរិច្ឆេទសវនកម្ម
2) ការជ្រើសរើសក្រុមសវនកម្ម (ជំនាញ/ជំនាញក្នុងការប្រាស្រ័យទាក់ទង)
3) និយមន័យនៃដៃគូសវនកម្ម (BSO ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកបច្ចេកទេស...)
4) ការបង្កើតកម្មវិធីសវនកម្មយោងទៅតាមស្ថានភាពរបស់ស្ថាប័ន
5) ការពិនិត្យឡើងវិញលើឯកសារ
6) សវនកម្មតាមទីតាំង
    - កិច្ចប្រជុំបើកសវនកម្ម
    - សវនកម្មយោងទៅតាមកម្មវិធី
    - កិច្ចប្រជុំបិទសវនកម្ម
7) របាយការណ៍សវនកម្ម
8) ការតាមដានបន្តលើសវនកម្ម

# គុណភាពនៃរបាយការណ៍សវនកម្ម

**ភាពមិនលម្អៀង**

យោបល់ និងទស្សនៈត្រូវបានបង្ហាញចេញមកក្នុងលក្ខណៈបែបកម្មវត្ថុ និងមិនលម្អៀង

**ភាពច្បាស់លាស់**

ភាសាដែលត្រូវបានប្រើប្រាស់គួរតែមានលក្ខណៈសាមញ្ញ និងត្រង់ៗ

**ភាពត្រឹមត្រូវ**

ព័ត៌មានដែលផ្តល់ឲ្យគួរតែមានភាពត្រឹមត្រូវ

**សង្ខេប**

របាយការណ៍គួរតែមានលក្ខណៈខ្លី

**ទាន់ពេលវេលា**

របាយការណ៍គួរត្រូវបានចេញភ្លាមៗបន្ទាប់ពីសវនកម្មត្រូវបានបញ្ចប់ (ឧ. ក្នុងរយៈពេលមួយខែ)

# ការតាមដានបន្តលើសកម្មភាពកែតម្រូវ

- កំណត់រកសកម្មភាពកែតម្រូវដែលនឹងត្រូវអនុវត្ត
- កំណត់ការទទួលខុសត្រូវសម្រាប់ការអនុវត្ត
- កំណត់រយៈពេលសម្រាប់ការអនុវត្ត
- កំណត់ថាតើសកម្មភាពកែតម្រូវ នឹងត្រូវបានប្រាស្រ័យទាក់ទងតាមរបៀបណា
- កំណត់ពេលវេលា ដើម្បីតាមដានបន្តលើអនុសាសន៍របស់សវនកម្ម

# ការវាយតម្លៃមន្ទីរពិសោធន៍

- ដើម្បីវាយតម្លៃលើការអនុវត្តការងារធៀបជាមួយបទដ្ឋាន
- ដើម្បីពិនិត្យតាមដានភាពអនុលោមតាមគោលនយោបាយសុវត្ថិភាព
- ប្រើប្រាស់ឧបករណ៍វាយតម្លៃមន្ទីរពិសោធន៍របស់អង្គការ WHO សម្រាប់សូចនាករជីវសុវត្ថិភាព៖
  - សុវត្ថិភាព និងបរិវេណជុំវិញ
  - មានឧបករណ៍ការពារបុគ្គល
  - ការប្រើប្រាស់ឧបករណ៍ការពារបុគ្គល
  - មាននីតិវិធី
  - ការបណ្តុះបណ្តាលស្តីពីសុវត្ថិភាព
  - លក្ខខណ្ឌសុវត្ថិភាពមន្ទីរពិសោធន៍
  - ការសម្លាប់មេរោគ និងការធ្វើឲ្យគ្មានមេរោគនៃឧបករណ៍
  - ការធ្វើឲ្យគ្មានមេរោគ
  - ការបោះចោលកាកសំណល់
  - សេវាសុខភាពបុគ្គលិក



# ឧបករណ៍វាយតម្លៃមន្ទីរពិសោធន៍ (LAT)

- ផ្តល់មគ្គុទេសក៍ ដើម្បីវាយតម្លៃមន្ទីរពិសោធ៍ និងប្រព័ន្ធមន្ទីរពិសោធន៍ជាតិ
- ពិពណ៌នាដំណើរការទូទៅសម្រាប់វាយតម្លៃមន្ទីរពិសោធន៍ និងផ្តល់កម្រងសំណួរ ដើម្បីជួយវាយតម្លៃលើប្រព័ន្ធមន្ទីរពិសោធន៍ជាតិ និងមន្ទីរពិសោធន៍ផ្សេងទៀត
- អាចត្រូវបានប្រើប្រាស់ ឬកែសម្រួល ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការក្នុងស្រុក ឬសេចក្តីត្រូវការលើចំណុចជាក់លាក់ណាមួយ ហើយបន្សុំជាមួយបរិបទនៃការវាយតម្លៃ

# ការត្រៀមសម្រាប់ធ្វើការវាយតម្លៃ

1) ស្ថាបនា និងត្រៀមក្រុមវាយតម្លៃ៖

- បុគ្គលិកមកពីក្រសួងសុខាភិបាល (និង/ឬក្រសួងដទៃ)
- ការិយាល័យប្រចាំប្រទេសរបស់ WHO
- ជំនាញការមន្ទីរពិសោធន៍ (អ្នកតំណាងមកពីមន្ទីរពិសោធន៍សុខភាពសាធារណៈ មន្ទីរពេទ្យ គ្លីនិកឯកជន ឬមកពីមន្ទីរពិសោធន៍នៃស្ថាប័នសិក្សាធិការ។ល។)
- អ្នកជំនាញផ្នែកសុខភាពសាធារណៈ អ្នកជំនាញអេពីដេមីសាស្ត្រ
- មន្ត្រីកម្មវិធីគ្រប់គ្រងជំងឺ (HIV របេង កម្មវិធីគ្រប់គ្រងជំងឺគ្រុនចាញ់ជាតិ និងផ្សេងទៀត)
- អង្គការមិនមែនរដ្ឋាភិបាល

# ការអនុវត្តការវាយតម្លៃ

**2) ធ្វើការសម្របដែលចាំបាច់ទៅតាមពិធីការនៃការវាយតម្លៃ**

ពិនត្យឡើងវិញលើ LAT/ កម្រងសំណួរជាប្រព័ន្ធ (LAT/ ប្រព័ន្ធ ) និង LAT/កម្រងសំណួរសម្រាប់គ្រឹះស្ថាន (LAT/គ្រឹះស្ថាន) និងកែសម្រួលយោងទៅតាមរចនាសម្ព័ន្ធ និងសេចក្តីត្រូវការរបស់មន្ទីរពិសោធន៍គោលដៅ

**3) ប្រមូលឯកសារដើម្បីពិនិត្យឡើងវិញ**

ឯកសារទាំងនេះ រួមមានដូចជា បទបញ្ញត្តិ គោលការណ៍ណែនាំ និងសៀវភៅណែនាំ

# ការអនុវត្តការវាយតម្លៃ

**4) ធ្វើផែនការសម្រាប់កិច្ចប្រជុំ ការសម្ភាសន៍ និងទស្សកិច្ចនៅមូលដ្ឋាន**

របៀបវារៈសម្រាប់ការវាយតម្លៃ គួរត្រូវបានរៀបចំឡើងដោយក្រុមការងារវាយតម្លៃ

**5) ការប្រមូលទិន្នន័យ**

ប្រើប្រាស់កម្រងសំណួរពីរ ដែលមានផ្តល់ជូននៅក្នុងឯកសារ Excel ដូចភ្ជាប់មកជាមួយ LAT/ ប្រព័ន្ធ និង LAT/គ្រឹះស្ថាន។ ការវាយតម្លៃអាចចែកទៅតាមក្រុមដើម្បីគ្របដណ្តប់លើវិស័យបច្ចេកទេស និងវិស័យភូមិសាស្ត្រផ្សេងៗគ្នា

# ការត្រៀមលទ្ធផលវាយតម្លៃ

6) ប្រជុំបូកសរុប និងផ្ទៀងផ្ទាត់ទិន្នន័យដែលប្រមូលបាន សូចនាករត្រូវបានគណនានៅក្នុងអំឡុងវាយតម្លៃមន្ទីរពិសោធន៍ (ពេលឯកសារ Excel ត្រូវបានប្រើប្រាស់) គួរត្រូវបានចែកទៅតាមប្រភេទ ហើយប្រៀបធៀបជាមួយលទ្ធផលថ្នាក់ជាតិ និងពិនិត្យផ្ទៀងផ្ទាត់ជាមួយប្រភពឯកសារដទៃ។

7) ការត្រៀមរបាយការណ៍វាយតម្លៃ

# ការត្រៀមលទ្ធផលវាយតម្លៃ

8)ការចែកចាយរបាយណ៍ការ ដើម្បីបញ្ជាក់ចំណុចខ្វះខាត មុនពេលប្រគល់ទៅកាន់អ្នកផ្តួចផ្តើមឲ្យមានការវាយតម្លៃ ( MoH ទីភ្នាក់ងារផ្តល់មូលនិធិ ឬអង្គការអន្តរជាតិ)

9) **ការផ្សព្វផ្សាយរបាយកាណ៍**

ដំណើរការផ្សព្វផ្សាយគួរត្រូវបានបញ្ជាក់ឲ្យច្បាស់ជាមួយអ្នកផ្តួចផ្តើមការវាយតម្លៃ ប្រសិនបើអ្នកផ្តួចផ្តើមនោះខុសពីអាជ្ញាធរជាតិ

# ឧបករណ៍វាយតម្លៃមន្ទីរពិសោធន៍ (LAT)

**4- BIOSAFETY, HYGIENE AND SECURITY**

| Safety and premises | 50% | Results Print | % for calcuation |
|---|---|---|---|
| Is access to, and use of laboratory technical areas controlled/restricted? | Y | Y | 100% |
| Is access to, and use of laboratory staff/office rooms controlled/restricted? | N | N | 0% |
| Is sample reception performed in room(s) separated from the laboratory examination room(s)? | N | N | 0% |
| Are any non technical areas clearly separated from sampling/technical rooms? | N | N | 0% |
| Space allocated is sufficient to perform the work without compromising the quality/safety of patients and staff? | Y | Y | 100% |
| Is there a separation between adjacent laboratory sections in which there are incompatible activities? | Y | Y | 100% |
| *(like for molecular biology, working places and resting places...)* | | | |

| Availability of personal protective equipment | 100% | Results Print | % for calcuation |
|---|---|---|---|
| Do you have sufficient quantities of: | | | |
| Gloves? | Y | Y | 100% |
| Clean Labcoat? | Y | Y | 100% |
| Surgical masks | Y | Y | 100% |
| N95 masks | Y | Y | 100% |
| Protective glasses/goggles? | Y | Y | 100% |
| Disinfectants (precise which ones as a comment) | Y | Y | 100% |
| Bleach, diluted 1:10 | | | |

| Personal protective equipment use | 33% | Results Print | % for calcuation |
|---|---|---|---|
| Does the laboratory staff use following at appropriate time/as per procedure? ( 1 never, 2 sometimes, 3 always) | | | |
| Clean Labcoat? | 3 | 3 | 100% |
| Gloves? | 2 | 2 | 50% |
| Masks | 2 | 2 | 50% |
| Protective glasses/goggles? | 1 | 1 | 0% |
| Protection screen (sample opening) | 1 | 1 | 0% |
| Is there a central service for labcoats/lab linen washing? | N | N | 0% |

# លទ្ធផល LAT

| Laboratory Assessment Summary | | | |
|---|---|---|---|
| **Full name of the laboratory** | Example Lab | Respondent #1 | Sapho By |
| Country | Cambodia | Respondent #2 | Bun Tuon |
| Province | Phnom Penh | Respondent #3 | Savuth Nov |
| Date | 24/10/2016 | | |
| Lab director name | Savuth Nov | | |
| Tel | 12998765 | | |
| Email | savuth.nov@lab.khgov | | |
| Laboratory type | CPA1 | | |
| Population officially covered by the lab | **Phnom Penh** | Assessor(s) | **Sokunna Sau, Monipheap Uch** |
| Number of samples received annually | **0** | Visit # | **1** |

| **Biosafety Indicator** | % |
|---|---|
| Safety and premises | 50% |
| Availability of personal protective equipment | 100% |
| Personal protective equipment use | 33% |
| Availability of procedures | 78% |
| Safety training | 50% |
| Laboratory safety conditions | 43% |
| Equipment disinfection and sterilization | 67% |
| Sterilization | 75% |
| Waste disposals | 40% |
| Staff health services | 33% |






# ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រងជីវហានិភ័យ

គោលបំណង៖

- ដើម្បីយល់ច្បាស់ថា ការគ្រប់គ្រងជីវហានិភ័យ រួមមានទាំងការវាយតម្លៃហានិភ័យ ការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងការអនុវត្ត
- ដើម្បីយល់អំពីគោលការណ៍គន្លឹះសំខាន់ៗនៃការវាយតម្លៃហានិភ័យ ការកាត់បន្ថយហានិភ័យ និងការគ្រប់គ្រងការអនុវត្ត
- ហ្វឹកហាត់ប្រើប្រាស់វិធីសាស្រ្តជាប្រព័ន្ធនៃការវាយតម្លៃ
- ដើម្បីទទួលបានជំនាញនៃ "ការរៀនសូត្ររបស់មនុស្ស-ពេញវ័យ" បន្ទាប់មកដើម្បីអាចផ្ទេរចំណេះដឹង និងជំនាញបន្តបានប្រកបដោយប្រសិទ្ធភាព
- មានសមត្ថភាពអាចអនុវត្តការវាយតម្លៃហានិភ័យបាន

# ខ្លឹមសារ

គួរគ្រូបដណ្តប់លើតម្រូវការជាមូលដ្ឋានសម្រាប់កម្មវិធីគ្រប់គ្រងជីវហានិភ័យប្រកបដោយប្រសិទ្ធភាព ហើយកែតម្រូវឲ្យស្របទៅតាមសេចក្តីត្រូវការរបស់មន្ទីរពិសោធន៍

- ទស្សនាទាន និងស័ព្ទបច្ចេកទេសនៃការវាយតម្លៃហានិភ័យ
- គំរូ AMP សម្រាប់ការគ្រប់គ្រងជីវហានិភ័យ
- វិធីសាស្ត្រវាយតម្លៃហានិភ័យ (RAM)៖ ការពិពណ៌នាអំពីជំហាននានាដើម្បីអនុវត្តការវាយតម្លៃហានិភ័យ
- សវនកម្ម និងអធិការកិច្ច
- គោលការណ៍ និងទ្រឹស្តីនៃ "បច្ចេកទេសការរៀនសូត្ររបស់មនុស្សពេញវ័យ"
- ការហ្វឹកហាត់ ការផ្តល់ការបណ្តុះបណ្តាល ការថតកំណត់ត្រាជាវីដេអូ និងការពិនិត្យឡើងវិញបែបវិជ្ជាជីវៈ ព្រមទាំងការផ្តល់យោបល់ត្រឡប់